**Declassified to Public**
**06 September 2012**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
Office of the Co-Investigating Judges
Bureau des Co-Juges d'instruction

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007**

# ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យដើម្បីបំបែកសំណុំរឿង
# Forwarding Order for the purpose of separation
# Ordonnance de soit-communiqué aux fins de disjonction

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច

បានឃើញវិធាន២១-៤នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

## ការរំលឹកអំពីនីតិវិធី និង សំអាងហេតុ

យោងតាមកំណត់ហេតុនៃការចូលខ្លួនលើកតំបូងនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៧ យើងបានប្រាប់អោយជនត្រូវចោទយ៉ាងច្បាស់អំពីអង្គហេតុនីមួយៗដែលយើងត្រូវបានបើកការស៊ើបសួរដោយដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ របស់លោក និង លោកស្រី សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ។ ម្យ៉ាងវិញទៀត ឌុចក៏បានទទួលដីកាបញ្ជូនរឿងឱ្យស៊ើបសួរថតចម្លងនៅថ្ងៃទី ២ សីហា ឆ្នាំ ២០០៧។ តាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះ សហព្រះរាជអាជ្ញាបានលើកឡើងនូវអង្គហេតុមួយចំនួនដែលអាចកំណត់ជាបទល្មើសដូចខាងក្រោម៖

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00146577



- ការរំលោភបំពានក្រមព្រហ្មទ័ណ្ឌឆ្នាំ ១៩៥៦ (មនុស្សឃាត ការធ្វើទារុណកម្ម និង ការធ្វើទុកបុកម្នេញដល់ពុទ្ធិសាសនិក និង សាសនិកឥស្លាម)
- បទល្មើសប្រល័យពូជសាសន៍ (លើពុទ្ធិសាសនិក ជនជាតិចាម និង វៀតណាម)
- បទល្មើសប្រឆាំងនឹងមនុស្សជាតិ (មនុស្សឃាត ការសំលាប់ផុតពូជ ការដាក់ជាទាសករ ការនិរទេស ការដាក់ឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុកបុកម្នេញ ដោយហេតុផលនយោបាយ ជាតិសាសន៍ និង សាសនា លើអតីតមន្ត្រីសាធារណៈរដ្ឋកម្ពុជា ជនសក្តិភូមិ ជនមូលធន និង គហបតី "ប្រជាជនថ្មី" "ធាតុមិនល្អ"ដែលគេសង្ស័យ ពុទ្ធិសាសនិក ជនជាតិចាម និង វៀតណាម និង អំពើអមនុស្សធម៌ ដទៃទៀត )
- ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩ (ការសំលាប់ដោយចេតនា ការធ្វើទារុណកម្ម ឬ ការប្រព្រឹត្តអមនុស្សធម៌ ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើអោយឈឺចាប់ខ្លាំងដោយចេតនា ដល់រាយកាយ និង សុខភាព ការបំផ្លាញ និង បង្កព្យសនកម្មធ្ងន់ធ្ងរដល់រាងកាយ និង សុខភាព ការបំផ្លាញ និង ការធ្វើអោយខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដោយគ្មានហេតុផលចាំបាច់ខាងផ្នែកយោធាដែលត្រូវបានអនុវត្តដោយខុសច្បាប់ និង ដោយគ្មានត្រាប្រណី ការដកហូតពីអ្នកទោសសង្គ្រាម ឬ ជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ទៀងទាត់ និង ការនិរទេស ឬ ផ្លាស់ទីលំនៅដោយបង្ខំ ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)។

អង្គហេតុមួយចំនួនក្នុងចំណោមអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ ត្រូវបានប្រព្រឹត្តឡើងក្រៅក្របខ័ណ្ឌ ស ២១ និង អង្គហេតុខ្លះទៀតត្រូវបានប្រព្រឹត្តឡើងក្នុងក្របខ័ណ្ឌនៃដំណើរការរបស់ ស ២១ នេះ។

អង្គហេតុដែលប្រព្រឹត្តឡើងក្រៅក្របខ័ណ្ឌ ស ២១ ទាមទារអោយមានការស៊ើបសួរស៊ីជម្រៅបន្ថែមទៀត ដែលការស៊ើបសួរនេះមិនអាចផ្តាច់ចេញពីការស៊ើបសួរដែលធ្វើឡើងចំពោះជនផ្សេងទៀតដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរឡើយ។

ផ្ទុយទៅវិញ អង្គហេតុដែលចោទចំពោះ ឌុច ក្នុងនាមគាត់ជាប្រធាន ស ២១ មានលក្ខណៈមិនស្មុគស្មាញ និង សាមញ្ញបំផុត។ ម្យ៉ាងវិញទៀត អង្គហេតុទាំងនេះមិនត្រូវបានជំទាស់ពីសំណាក់ជនត្រូវចោទទេ។ ដូច្នេះ អង្គហេតុនេះ



CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION" E.C.C.C * C.E.T.C

00146578

ឯកសារ D17

អាចនឹងត្រូវបញ្ជូនទៅជំនុំជម្រះនៅក្នុងរយៈពេលប៉ុន្មានខែខាងមុខ ដោយមិនចាំបាច់រង់ចាំលទ្ធផលស៊ើបសួរបន្ថែម ដែលលើកឡើងខាងលើឡើយ។

យើងត្រូវមានដំណោះស្រាយមួយអោយបានលឿនចំពោះករណី ឌុច ដោយហេតុថាជននេះត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងក្របខ័ណ្ឌនីតិវិធីផ្សេងអស់រយៈពេល ៨ ឆ្នាំមកហើយ ដូចដែលមានរៀបរាប់នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ៣១ កក្កដា ២០០៧។ ម្យ៉ាងវិញទៀត ការបើកសវនាការជាសាធារណៈនៅក្នុងរយៈពេលឆាប់ៗមានសារៈសំខាន់ជាសារវ័ន្ត ដល់ភាពដែលអាចជឿជាក់បានរបស់តុលាការ ដោយពិនិត្យមើលលើអតីតភាពនៃអង្គហេតុរឿងក្តីនេះ។

យល់ឃើញថា ដោយពិនិត្យមើលលើចំនុចទាំងអស់ខាងដើម និង ជាគុណប្រយោជន៍ដល់ដំណើរការល្អនៃការស្វែងរកយុត្តិធម៌ មានការចាំបាច់ដែលត្រូវបំបែកករណី ឌុច ក្នុងរឿងដែលគាត់ជាប្រធាន ស ២១។ ដើម្បីអោយមានលក្ខណៈសាមញ្ញ ការបំបែកសំណុំរឿងនេះត្រូវរៀបចំធ្វើឡើងមុននឹងដាក់អោយ ស្ថិតនៅក្រោមការត្រួតពិនិត្យជនសង្ស័យដទៃទៀត ដែលការដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យនេះជាសំខាន់ នាំឱ្យត្រូវមានសេចក្តីសម្រេចបំបែកសំណុំរឿងជាបន្ទាន់។

## ហេតុដូចនេះសម្រេច

សូមបញ្ជូនសំណុំរឿងស៊ើបសួរទៅសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញដើម្បីពិនិត្យ និង ផ្តល់យោបល់លើការបំបែកសំណុំរឿង **ឌុច** ក្នុងរឿងដែលគាត់ជាប្រធាន **ស ២១**។

សូមជម្រាបដល់សហព្រះរាជអាជ្ញាថាត្រូវផ្តល់យោបល់របស់ខ្លួនមកយើងវិញមុនថ្ងៃទី ១៩ កញ្ញា ២០០៧

ធ្វើនៅភ្នំពេញ ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ ២០០៧

**សហចៅក្រមស៊ើបអង្កេត**
**Co- Investigating Judges**
**Co-juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941